ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២១ លេខ៨៣ ត្រីមាសទី០៤ ឆ្នាំ២០២១

# រាជកិច្ច

ផ្សាយចេញពី

## ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


៥-១០-២០២១ -ព្រះរាជក្រម នស/រកម/១០២១/០០៩ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃ សាធារណរដ្ឋប្រជាមានិតចិន

*(សម្រាប់ឧបសម្ព័ន្ធបន្ថែម អាចមកពិនិត្យមើលផ្ទាល់នៅនាយកដ្ឋានតម្កល់ឯកសារជាតិ)* ១០២៤១


### ២~ព្រះរាជក្រឹត្យ


២៥-១២-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៧៦ ស្តីពី ការតែងតាំងគោរមងារព្រះរាជាគណៈ នៃ គណៈមហានិកាយ នៅព្រះរាជាណាចក្រកម្ពុជា ១៣៨អង្គ ១០២៤៣


## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ


២៨-៩-២០២១ -អនុក្រឹត្យលេខ ១៩១ អនក្រ.បក ស្តីពី ការធ្វើអនុប្បយោគផ្ទៃដីទំហំ ១ ១៥៤ (មួយពាន់មួយរយ ហាសិបបួន) ហិកតា ស្ថិតនៅក្នុងឧទ្យានជាតិបុទុមសាគរ ភូមិសាស្រ្ត ឃុំតានួន ស្រុក បុទុមសាគរ ខេត្តកោះកុង ជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បីដោះស្រាយជូនប្រជាពលរដ្ឋ រងផលប៉ះពាល់ជាមួយក្រុមហ៊ុន Union Development Group Co…,Ltd និងត្រៀមបម្រុងទុក សម្រាប់អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ១០២៤៨

៣០-១២-២០២១ -អនុក្រឹត្យលេខ ៥៩៩ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១០២៥១


## III~ការងារបណ្តាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


២៦-៣-២០២១ -ប្រកាសលេខ១៩៣ សហវ.ប្រក ស្តីពី វិធាន និងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ ១០២៥៤

២៩-៣-២០២១ -ប្រកាសលេខ១៩៦ សហវ.ប្រក ស្តីពី វិធាន និងនីតិវិធីនៃការព្យួរការបំពេញបែបបទបញ្ចេញ ទំនិញពីគយចំពោះទំនិញនាំចេញ-នាំចូលល្មើសកម្មសិទ្ធិបញ្ញា ១០២៥៨


### ២~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍


៦-៧-២០២១ -ប្រកាសលេខ ២២១ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ចាន់កូ ថេកស្ថាយ (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ភួយ ស្រោមពូក និងស្រោមខ្នើយ ១០២៦៤

៦-៧-២០២១ -ប្រកាសលេខ ២២៥ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ីមប៉ាក (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតវ៉ាលិស និងកាបូបគ្រប់ប្រភេទ ១០២៦៧

២១-១០-២០២១ -ប្រកាសលេខ ៣៧៩ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីន ស៊ីងលី លេឌើរ ប្រដាក ឯ.ក បង្កើតរោងចក្រ ផលិតកាបូបគ្រប់ប្រភេទ ១០២៧០

២៦-១០-២០២១ -ប្រកាសលេខ ៣៨០ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្គាវ ដា បង្កើតរោងចក្រ ផលិតគ្រឿងបន្សំស្បែកជើង ១០២៧៣

២៦-១០-២០២១ -ប្រកាសលេខ ៣៨១ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ម៉ុង ឫទ្ធី វិនិយោគទុន ដំណាំដូងប្រេង កម្ពុជា បង្កើតរោងចក្រ ចម្រាញ់ដូងប្រេង ១០២៧៦

២៦-១០-២០២១ -ប្រកាសលេខ ៣៨២ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជីប ម៉ុង អ៊ីនដាស្ទ្រីស៍ (ស៊ីអិមអាយ) ឯ.ក បង្កើតរោងចក្រ ផលិតក្បឿង ១០២៧៩

២៦-១០-២០២១ -ប្រកាសលេខ ៣៨៣ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជីប ម៉ុង អ៊ីនដាស្ទ្រីស៍ (ស៊ីអិមអាយ) ឯ.ក បង្កើតរោងចក្រ ផលិតទុយោ ១០២៨២

២៧-១០-២០២១ -ប្រកាសលេខ ៣៨៤ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យីយ៉ា ភែកឃីជីង (កម្ពុជា) ឯ.ក បង្កើតរោងចក្រ ផលិតប្រអប់ក្រដាសដាក់វត្ថុអនុស្សាវរីយ៍គ្រប់ប្រភេទ ១០២៨៥

២៧-១០-២០២១ -ប្រកាសលេខ ៣៨៥ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខូឡាបូរេសិន ភែកឃីជីង មេធៀរៀល ប្រូដាក់ ឯ.ក បង្កើតរោងចក្រ ផលិតគ្រឿងបន្សំកាបូប និងគ្រឿងបន្សំស្បែកជើង ១០២៨៨

២៧-១០-២០២១ -ប្រកាសលេខ ៣៨៦ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឌី.ជី.ស៊ី គ្រុប បង្កើតរោងចក្រ កែច្នៃកៅស៊ូក្រែប ១០២៩១

៣-១១-២០២១ -ប្រកាសលេខ ៣៨៧ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ប៊ីល អាប់ (ខេមបូឌា) មេនូហ្វេកឈ័ររីង លីមីធីត បង្កើតរោងចក្រ ផលិតប្រដាប់ព្យួរសម្លៀកបំពាក់ និងស្លាកសញ្ញាសម្លៀកបំពាក់ ១០២៩៤

៣-១១-២០២១ -ប្រកាសលេខ ៣៨៨ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីងសុង អ៊ិនដាសស្ទ្រៀល (ខេមបូឌា) បង្កើតរោងចក្រ កែច្នៃដំឡូងមី ១០២៩៧

៣-១១-២០២១ -ប្រកាសលេខ ៣៨៩ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីន ចេន ហ្វ៊ូ ហ៊ែនឌី-ក្រាហ្វ & ហោវ៉េរ (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតតុក្កតា និងវត្ថុអនុស្សាវរីយ៍គ្រប់ប្រភេទ ១០៣០០

៣-១១-២០២១ -ប្រកាសលេខ ៣៩០ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ែដ្យាយល៍ ស្វេតចឺ (ខេមបូឌា) បង្កើតរោងចក្រ ចាក់ និងកាត់ដេរសម្លៀកបំពាក់ ១០៣០៣

៣-១១-២០២១ -ប្រកាសលេខ ៣៩១ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន គីស៊ីន (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ កាត់ដេរ និងបោកគក់សម្លៀកបំពាក់ ១០៣០៦

៣-១១-២០២១ -ប្រកាសលេខ ៣៩២ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ផាក ហេនប៉ែក (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតកាបូបគ្រប់ប្រភេទ ១០៣០៩

| | | |
|---|---|---|
| ៣-១១-២០២១ | -ប្រកាសលេខ ៣៩៣ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជីជី ហ្វេសិន (ខេមបូឌា) ឯ.ក បង្កើតសាខារោងចក្រកាត់ដេរសម្លៀកបំពាក់ | ១០៣១២ |
| ៥-១១-២០២១ | -ប្រកាសលេខ ៣៩៤ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន សាន់នីខន (ខេមបូឌា) អឹកែវឹល ឯ.ក បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ | ១០៣១៥ |
| ៥-១១-២០២១ | -ប្រកាសលេខ ៣៩៥ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អូសិន អឹកែវឹល មេនូ-ហ្វេកធឺរីង ឯ.ក បង្កើតសាខារោងចក្រ កាត់ដេរសម្លៀកបំពាក់ | ១០៣១៨ |
| ៥-១១-២០២១ | -ប្រកាសលេខ ៣៩៦ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ុមី (ខេមបូឌា) វ៉ាយរីង ស៊ីស្ទឹម បង្កើតសាខារោងចក្រ ផលិតខ្សែភ្លើងគ្រឿងបង្គុំអេឡិចត្រូនិចសម្រាប់រថយន្ត | ១០៣២១ |


## ៣~ទីស្តីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល


| | | |
|---|---|---|
| ២២-១២-២០២០ | -ប្រកាសលេខ ០៧៤៧ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៧៤៧ រថ.អប្រក.លអ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២០ | ១០៣២៤ |
| ២២-១២-២០២០ | -ប្រកាសលេខ ០៧៤៨ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០៧៤៨ រថ.អប្រក.លអ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២០ | ១០៣២៨ |
| ២២-១២-២០២០ | -ប្រកាសលេខ ០៧៤៩ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៧៤៩ រថ.អប្រក.លអ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២០ | ១០៣៣២ |
| ២២-១២-២០២០ | -ប្រកាសលេខ ០៧៥០ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០៧៥០ រថ.អប្រក.លអ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២០ | ១០៣៣៦ |
| ២២-១២-២០២០ | -ប្រកាសលេខ ០៧៥១ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៧៥១ រថ.អប្រក.លអ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២០ | ១០៣៤០ |
| ២២-១២-២០២០ | -ប្រកាសលេខ ០៧៥២ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៧៥២ រថ.អប្រក.លអ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២០ | ១០៣៤៤ |
| ២២-១២-២០២០ | -ប្រកាសលេខ ០៧៥៣ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០៧៥៣ រថ.អប្រក.លអ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២០ | ១០៣៤៨ |
| ២៤-១២-២០២០ | -ប្រកាសលេខ ០៧៥៤ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៧៥៤ រថ.អប្រក.លអ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០២០ | ១០៣៥២ |
| ២៨-១២-២០២០ | -ប្រកាសលេខ ០៧៥៥ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៧៥៥ រថ.អប្រក.លអ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០២០ | ១០៣៥៦ |
| ៣០-១២-២០២០ | -ប្រកាសលេខ ០៧៥៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៧៥៦ រថ.អប្រក.លអ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០២០ | ១០៣៦០ |


## ៤~ទីស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌


| | | |
|---|---|---|
| ៩-៦-២០២១ | -ប្រកាសលេខ ០៧៩ កយ.ប្រក/២១ ស្តីពី ការផ្លាស់ក្រឡាបញ្ជី | ១០៣៦៤ |

# ព្រះរាជក្រម

## យើង

នស/រកម/១០២១/០០៧

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ នាសម័យប្រជុំពេញអង្គលើកទី៧ នីតិកាលទី៤ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ច្បាប់
## ស្ដីពី
## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន

**មាត្រា១ .-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខានៅរាជធានីភ្នំពេញ នាថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា២ .-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។

**មាត្រា៣ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃអង្គារ ១៤រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ២០២១

នស/រកម/១០២១/០១៣

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្ថលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្ដិ**

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រី ប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៩៧៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៦/២០៧ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** តែងតាំងគោរមងារព្រះរាជាគណៈ នៃគណៈមហានិកាយ នៅព្រះរាជាណាចក្រកម្ពុជា ១៣៨អង្គ :

| | | | | |
|---|---|---|---|---|
| ១-ព្រះសិរីធម្មញាណ | **សុខ ថាន** | ឱ្យឡើងទីជា | **ព្រះទេពមុនី** | ព្រះរាជាគណៈថ្នាក់ចត្វា |
| ២-ព្រះឥន្ទកោសល្យ | **មុំ សុខឿន** | ឱ្យឡើងទីជា | **ព្រះវិសុទ្ធញ្ញាណ** | ព្រះរាជាគណៈថ្នាក់ចត្វា |
| ៣-ព្រះបាឡាត់មណ្ឌលានុរ័ក្ខ | **ពេជ្រ សុភ័ក្រ** | ឱ្យឡើងទីជា | **ព្រះវិមលត្ថេរ** | ព្រះរាជាគណៈកិត្តិយស |
| ៤-ព្រះគ្រូវិមលចន្ទ្រា | **ម៉ៅ សាវី** | ឱ្យឡើងទីជា | **ព្រះកិត្តិធម្មលក្ខណ៍** | ព្រះរាជាគណៈកិត្តិយស |
| ៥-ព្រះគ្រូរតនមុនី | **ឡុង សុផល** | ឱ្យឡើងទីជា | **ព្រះរតនពោធិមុនី** | ព្រះរាជាគណៈកិត្តិយស |
| ៦-ព្រះគ្រូឧទ័យវង្សា | **គិន ផល្លី** | ឱ្យឡើងទីជា | **ព្រះឥន្ទានុបាល** | ព្រះរាជាគណៈកិត្តិយស |
| ៧-ព្រះគ្រូធម្មវិបុលញាណ | **ឡោ សុខ** | ឱ្យឡើងទីជា | **ព្រះយសសិរីមុនី** | ព្រះរាជាគណៈកិត្តិយស |
| ៨-ព្រះគ្រូនិម្មលធម្មល័ក្ខណ៍ | **សោម ជាន** | ឱ្យឡើងទីជា | **ព្រះនិម្មលធម្មមុនី** | ព្រះរាជាគណៈកិត្តិយស |
| ៩-ព្រះ[illegible]បញ្ញោ | **សុខ គឹមឆុន** | ឱ្យឡើងទីជា | **ព្រះវិន័យធម្មធារ៍** | ព្រះរាជាគណៈកិត្តិយស |
| ១០-[illegible]ទី | **ឌុន ចាន់ថារី** | ឱ្យឡើងទីជា | **ព្រះលេខាកោសល** | ព្រះរាជាគណៈកិត្តិយស |
| [illegible]បិត[illegible]ចារ្យ | **នី សុខបញ្ញា** | ឱ្យឡើងទីជា | **ព្រះមង្គលវិជ្ជា** | ព្រះរាជាគណៈកិត្តិយស |
| [illegible]មុនី | **យ៉េន វណ្ណី** | ឱ្យឡើងទីជា | **ព្រះឧត្តមលិខិត** | ព្រះរាជាគណៈកិត្តិយស |

| | | | | |
|---|---|---|---|---|
| ១៣-ព្រះគ្រូជ័យសោភ័ណ | ជា សិរីវុឌ្ឍន៍ | ឱ្យឡើងទីជា | ព្រះកិត្តិសីលញាណ | ព្រះរាជាគណៈកិត្តិយស |
| ១៤-ព្រះគ្រូរតនធម្មញាណ | ម៉ា សុភ័ក្រ្ត | ឱ្យឡើងទីជា | ព្រះរតនធម្មធារ៍ | ព្រះរាជាគណៈកិត្តិយស |
| ១៥-ព្រះគ្រូថាវរធម្មញាណ | សាន់ ស៊ីម | ឱ្យឡើងទីជា | ព្រះថាវរធម្មវេទ្យា | ព្រះរាជាគណៈកិត្តិយស |
| ១៦-ព្រះគ្រូសុវណ្ណមុនីខេមរវង្សី | សម សុវណ្ណ | ឱ្យឡើងទីជា | ព្រះសុវណ្ណខេមរវង្សី | ព្រះរាជាគណៈកិត្តិយស |
| ១៧-ព្រះគ្រូរាជមុនីញាណ | ឃាន វិសា | ឱ្យឡើងទីជា | ព្រះរាជមុនីញាណ | ព្រះរាជាគណៈកិត្តិយស |
| ១៨-ព្រះគ្រូពោធិវង្សា | ជួប ជឿន | ឱ្យឡើងទីជា | ព្រះពាក្យលសត្ថា | ព្រះរាជាគណៈកិត្តិយស |
| ១៩-ព្រះគ្រូធម្មជោតិញាណ | គ្រិស ស៊ីនួន | ឱ្យឡើងទីជា | ព្រះកិត្តិធម្មរតន៍ | ព្រះរាជាគណៈកិត្តិយស |
| ២០-ព្រះគ្រូធម្មពោធិញាណ | ទឹម សំអុល | ឱ្យឡើងទីជា | ព្រះមុនីធម្មធារ៍ | ព្រះរាជាគណៈកិត្តិយស |
| ២១-ព្រះគ្រូចិត្តវង្សា | វ៉ាំង តារម្យ | ឱ្យឡើងទីជា | ព្រះធម្មវង្សី | ព្រះរាជាគណៈកិត្តិយស |
| ២២-ព្រះគ្រូធម្មបាលវង្សា | រីក សាម្ង | ឱ្យឡើងទីជា | ព្រះយុត្តាភិរ័ក្ខ | ព្រះរាជាគណៈកិត្តិយស |
| ២៣-ព្រះគ្រូញាណសោភ័ណ | មិត្ត តានិត្យ | ឱ្យឡើងទីជា | ព្រះជោតិសិរីញាណ | ព្រះរាជាគណៈកិត្តិយស |
| ២៤-ព្រះគ្រូសង្ឃភ័ទ្ទរិទ្ធិញាណ | ទេព ច័ន្ទរស្មី | ឱ្យឡើងទីជា | ព្រះមុនីបញ្ញាញាណ | ព្រះរាជាគណៈកិត្តិយស |
| ២៥-ព្រះគ្រូវិន័យសត្ថាមុនី | ប្រាក់ សុខ | ឱ្យឡើងទីជា | ព្រះពាក្យលមុនី | ព្រះរាជាគណៈកិត្តិយស |
| ២៦-ព្រះគ្រូសង្ឃានុរ័ក្ខវង្សា | ហុក គីមហេង | ឱ្យឡើងទីជា | ព្រះព្រហ្មវិន័យ | ព្រះរាជាគណៈកិត្តិយស |
| ២៧-ព្រះគ្រូកោសលមុនីវង្សី | ហោ ហ៊ីច | ឱ្យឡើងទីជា | ព្រះកោសលមេធា | ព្រះរាជាគណៈកិត្តិយស |
| ២៨-ព្រះគ្រូសិរីវឌ្ឍាភិមុនី | សុខ ពិសិដ្ឋ | ឱ្យឡើងទីជា | ព្រះរតនវេជ្ជានុបាល | ព្រះរាជាគណៈកិត្តិយស |
| ២៩-ព្រះគ្រូធម្មរតនវិជ្ជា | ឆៃ សៅ | ឱ្យឡើងទីជា | ព្រះកុសលសត្ថា | ព្រះរាជាគណៈកិត្តិយស |
| ៣០-ព្រះគ្រូសិរីវិក្ខិតមុនី | ផន សុជាតិ | ឱ្យឡើងទីជា | ព្រះវឌ្ឍនធម្មធារ៍ | ព្រះរាជាគណៈកិត្តិយស |
| ៣១-ព្រះគ្រូពោធិមុនីវង្សា | ខុន ឃាន់ | ឱ្យឡើងទីជា | ព្រះសទ្ធាភិមង្គល | ព្រះរាជាគណៈកិត្តិយស |
| ៣២-ព្រះគ្រូយុត្តការីវង្សា | សុខ បាយ័ន | ឱ្យឡើងទីជា | ព្រះសម្ភារមុនី | ព្រះរាជាគណៈកិត្តិយស |
| ៣៣-ព្រះគ្រូចរិយាធម្មញាណ | អ៊ិត វាសនា | ឱ្យឡើងទីជា | ព្រះរាមវេជ្ជាចារ្យ | ព្រះរាជាគណៈកិត្តិយស |
| ៣៤-ព្រះគ្រូបញ្ញាភិរ័តន៍ | ឌិន សាង | ឱ្យឡើងទីជា | ព្រះវិជ័យសត្ថាចារ្យ | ព្រះរាជាគណៈកិត្តិយស |
| ៣៥-ព្រះគ្រូវរធម្មបាលមុនី | សុង ពិសិទ្ធ | ឱ្យឡើងទីជា | ព្រះសុភបញ្ញាមុនី | ព្រះរាជាគណៈកិត្តិយស |
| ៣៦-ព្រះគ្រូសង្ឃបាលមុនី | សត់ សុភ័ក្រ | ឱ្យឡើងទីជា | ព្រះរាមានុញាណ | ព្រះរាជាគណៈកិត្តិយស |
| ៣៧-ព្រះគ្រូវិសុទ្ធមេធា | ម៉ី យឹន | ឱ្យឡើងទីជា | ព្រះរាមានុធម្ម | ព្រះរាជាគណៈកិត្តិយស |
| ៣៨-ព្រះគ្រូបញ្ញាមុនីញាណ | ប៉ែន សេដ្ឋា | ឱ្យឡើងទីជា | ព្រះខេមរត្ថេរ | ព្រះរាជាគណៈកិត្តិយស |
| ៣៩-ព្រះគ្រូឃោសាភិមុនី | ទ៉េត សុគន្ធា | ឱ្យឡើងទីជា | ព្រះខន្តិភោវិទ | ព្រះរាជាគណៈកិត្តិយស |
| ៤០-ព្រះគ្រូវិបុលវិន័យមុនី | ជៅ វ៉ាន់ដេត | ឱ្យឡើងទីជា | ព្រះកុសលវិចិត្រ | ព្រះរាជាគណៈកិត្តិយស |
| ៤១-ព្រះគ្រូអម្ពរសីលគុណ | សេក ម៉ៅ | ឱ្យឡើងទីជា | ព្រះរតនបញ្ញានុរ័ក្ខ | ព្រះរាជាគណៈកិត្តិយស |
| ៤២-ព្រះគ្រូធម្មកោវិទ | ឈុន ឌីណា | ឱ្យឡើងទីជា | ព្រះវិសុទ្ធិចរិយានុបាល | ព្រះរាជាគណៈកិត្តិយស |
| ៤៣-ព្រះគ្រូកល្យាណកិសិរី | ម៉ា សារុន | ឱ្យឡើងទីជា | ព្រះខន្តិសោភ័ណ | ព្រះរាជាគណៈកិត្តិយស |
| ៤៤-ព្រះគ្រូឃោសកិញាណ | ច័ន្ទ សុវណ្ណ | ឱ្យឡើងទីជា | ព្រះយសសិរីធម្ម | ព្រះរាជាគណៈកិត្តិយស |
| ៤៥-ព្រះគ្រូបញ្ញាវិសុទ្ធិវេទី | ជុំ សំណាង | ឱ្យឡើងទីជា | ព្រះព្រហ្មសីលវ័ន្ត | ព្រះរាជាគណៈកិត្តិយស |
| ៤៦-ព្រះគ្រូបវរសត្ថាញាណ | អ៊ុំ សារុំ | ឱ្យឡើងទីជា | ព្រះបទុមសីលាចារ្យ | ព្រះរាជាគណៈកិត្តិយស |
| ៤៧-ព្រះគ្រូអភិបាលសិរីយស | ប៊ុន សំអុល | ឱ្យឡើងទីជា | ព្រះវិជ័យសោភ័ណ | ព្រះរាជាគណៈកិត្តិយស |
| ៤៨-ព្រះគ្រូសិរីមង្គលកោវិទ | ទ៉េង សុវុធ | ឱ្យឡើងទីជា | ព្រះខេមវិជ័យ | ព្រះរាជាគណៈកិត្តិយស |
| ៤៩-ព្រះគ្រូបញ្ញាធម្មមុនី | ឌិក សារិន | ឱ្យឡើងទីជា | ព្រះយុត្តានុរ័ក្ខ | ព្រះរាជាគណៈកិត្តិយស |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| | | | | |
|---|---|---|---|---|
| ៥០-ព្រះគ្រូសិរីសត្ថា | យឿម រដ្ឋសភា | ឱ្យឡើងទីជា | ព្រះពុទ្ធរង្សី | ព្រះរាជាគណៈកិត្តិយស |
| ៥១-ព្រះគ្រូធម្មវិសុទ្ធិញាណ | យឿន សុខឡឿន | ឱ្យឡើងទីជា | ព្រះជ័យសោភ័ណ | ព្រះរាជាគណៈកិត្តិយស |
| ៥២-ព្រះគ្រូសង្ឃមុនី | ស្រេង ស្រ៊ន | ឱ្យឡើងទីជា | ព្រះកោសលានុបាល | ព្រះរាជាគណៈកិត្តិយស |
| ៥៣ ព្រះគ្រូកល្យាណរតនមុនី | ឈុំ សារ៉ាន | ឱ្យឡើងទីជា | ព្រះវិចិត្រសីលាចារ្យ | ព្រះរាជាគណៈកិត្តិយស |
| ៥៤-ព្រះគ្រូកល្យាណោ | មោគ បាន | ឱ្យឡើងទីជា | ព្រះវិមលសរណធម្ម | ព្រះរាជាគណៈកិត្តិយស |
| ៥៥-ព្រះគ្រូសុវណ្ណធម្មសំវរ | រស់ សុវណ្ណា | ឱ្យឡើងទីជា | ព្រះសិរីរតនាចារ្យ | ព្រះរាជាគណៈកិត្តិយស |
| ៥៦-ព្រះគ្រូធម្មសរណមុនី | ចាន់ សុធា | ឱ្យឡើងទីជា | ព្រះសរណានុរ័ក្ខធម្ម | ព្រះរាជាគណៈកិត្តិយស |
| ៥៧-ព្រះគ្រូបទុមមុនី | សាន់ ឡេ | ឱ្យឡើងទីជា | ព្រះមេត្តាវរវេទី | ព្រះរាជាគណៈកិត្តិយស |
| ៥៨-ព្រះគ្រូចន្ទមង្គល | អ៊ឹម សុខសាន្ត | ឱ្យឡើងទីជា | ព្រះសិរីគុណាញាណ | ព្រះរាជាគណៈកិត្តិយស |
| ៥៩-ព្រះគ្រូសរណានុរ័ក្ខធម្ម | ស៊ិន សុភាព | ឱ្យឡើងទីជា | ព្រះសទ្ធានុលក្ខណ៍ | ព្រះរាជាគណៈកិត្តិយស |
| ៦០-ព្រះគ្រូវិបស្សនាចារ្យ | ស៊ើន សុកោសល | ឱ្យឡើងទីជា | ព្រះវិសារញាណ | ព្រះរាជាគណៈកិត្តិយស |
| ៦១-ព្រះគ្រូឧត្តរវង្សី | អ៊ុក ឌ៉ូច | ឱ្យឡើងទីជា | ព្រះសតិមង្គល | ព្រះរាជាគណៈកិត្តិយស |
| ៦២-ព្រះគ្រូរតនមុនីឧត្តម | សាម សំបូរ | ឱ្យឡើងទីជា | ព្រះវិចិត្រមុនីញាណ | ព្រះរាជាគណៈកិត្តិយស |
| ៦៣-ព្រះគ្រូវឌ្ឍនាភិរ័ក្ខ | ភ្លួច សុមាន | ឱ្យឡើងទីជា | ព្រះជ័យកោសល | ព្រះរាជាគណៈកិត្តិយស |
| ៦៤-ព្រះគ្រូឥន្ទធម្មញាណ | យ៉ាន់ ខៀន | ឱ្យឡើងទីជា | ព្រះឃោសាភិបាល | ព្រះរាជាគណៈកិត្តិយស |
| ៦៥-ព្រះគ្រូបវរសីលមុនី | ប៉ែន ភក្ត្រា | ឱ្យឡើងទីជា | ព្រះពោធិកុលសិរី | ព្រះរាជាគណៈកិត្តិយស |
| ៦៦-ព្រះភិក្ខុសិរីវិសុទ្ធិ | ផន្ទ សុផល | ឱ្យឡើងទីជា | ព្រះវិសុទ្ធាភិរ័តន៍ | ព្រះរាជាគណៈកិត្តិយស |
| ៦៧-ព្រះភិក្ខុធម្មបាលោ | កែវ មុនី | ឱ្យឡើងទីជា | ព្រះរតនមុនីញាណ | ព្រះរាជាគណៈកិត្តិយស |
| ៦៨-ព្រះភិក្ខុបញ្ញាវិសាលោ | ជឹម ពៅ | ឱ្យឡើងទីជា | ព្រះរាមសោភ័ណ | ព្រះរាជាគណៈកិត្តិយស |
| ៦៩-ព្រះភិក្ខុសច្ចកល្យាណោ | យ៉ន សុខសាន្ត | ឱ្យឡើងទីជា | ព្រះសច្ចកល្យាណ | ព្រះរាជាគណៈកិត្តិយស |
| ៧០-ព្រះភិក្ខុរតនសីលោ | អ៊ុក ឫទ្ធី | ឱ្យឡើងទីជា | ព្រះយសសិរីវង្សា | ព្រះរាជាគណៈកិត្តិយស |
| ៧១-ព្រះភិក្ខុនាថបណ្ឌិតោ | នាង សីលា | ឱ្យឡើងទីជា | ព្រះញាណយ្យត្ថេរ | ព្រះរាជាគណៈកិត្តិយស |
| ៧២-ព្រះភិក្ខុរតនជោតោ | ហេង បូរ៉ា | ឱ្យឡើងទីជា | ព្រះយុត្តានុធម្ម | ព្រះរាជាគណៈកិត្តិយស |
| ៧៣-ព្រះភិក្ខុឥន្ទមុនី | គឿន ធាវ័ន្ត | ឱ្យឡើងទីជា | ព្រះឥន្ទកោសល្យ | ព្រះរាជាគណៈកិត្តិយស |
| ៧៤-ព្រះភិក្ខុអានន្ទោ | នុច មុនី | ឱ្យឡើងទីជា | ព្រះសិរីធម្មញាណ | ព្រះរាជាគណៈកិត្តិយស |
| ៧៥-ព្រះភិក្ខុមង្គលកាមោ | យ៉ង់ ម៉ាច | ឱ្យឡើងទីជា | ព្រះឱវាទមុនី | ព្រះរាជាគណៈកិត្តិយស |
| ៧៦-ព្រះភិក្ខុសុវណ្ណប្បញ្ញោ | ឌន ស៊ីដន | ឱ្យឡើងទីជា | ព្រះរាមានុបាល | ព្រះរាជាគណៈកិត្តិយស |
| ៧៧-ព្រះភិក្ខុកន្តធម្មោ | ហែម សុធឿន | ឱ្យឡើងទីជា | ព្រះរាមាភិរ័តន៍ | ព្រះរាជាគណៈកិត្តិយស |
| ៧៨-ព្រះភិក្ខុសុវណ្ណជោតោ | អ៊ុច សុខុន | ឱ្យឡើងទីជា | ព្រះកុសលវង្សី | ព្រះរាជាគណៈកិត្តិយស |
| ៧៩-ព្រះភិក្ខុតបរត្តោ | ស៊ី សំណាង | ឱ្យឡើងទីជា | ព្រះកុសលមេធា | ព្រះរាជាគណៈកិត្តិយស |
| ៨០-ព្រះភិក្ខុខេមចិត្តោ | ស៊ឹង ចិនសៃ | ឱ្យឡើងទីជា | ព្រះចិត្តសោភ័ណ | ព្រះរាជាគណៈកិត្តិយស |
| ៨១-ព្រះភិក្ខុព្រហ្មកេស | ហេង ម៉ិនសាម | ឱ្យឡើងទីជា | ព្រះកុសលមង្គល | ព្រះរាជាគណៈកិត្តិយស |
| ៨២-ព្រះភិក្ខុអគ្គជោតោ | សុច សឿម | ឱ្យឡើងទីជា | ព្រះសេដ្ឋានុបាល | ព្រះរាជាគណៈកិត្តិយស |
| ៨៣-ព្រះភិក្ខុព្រហ្មបញ្ញោ | សន ស៊ីណាត | ឱ្យឡើងទីជា | ព្រះសីលានុលក្ខណ៍ | ព្រះរាជាគណៈកិត្តិយស |
| ៨៤-ព្រះភិក្ខុឥន្ទកោសល្យ | ហ៊ីង ចាន់ណា | ឱ្យឡើងទីជា | ព្រះចុល្លត្ថេរ | ព្រះរាជាគណៈកិត្តិយស |
| ៨៥-ព្រះភិក្ខុសម្មដ្ឋធម្មោ | សេង សុភ័ស្ត | ឱ្យឡើងទីជា | ព្រះយុត្តានុបាល | ព្រះរាជាគណៈកិត្តិយស |
| ៨៦-ព្រះភិក្ខុបញ្ញាបទីបោ | សយ ម៉ិន | ឱ្យឡើងទីជា | ព្រះយសមុនីលក្ខណ៍ | ព្រះរាជាគណៈកិត្តិយស |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| | | | | |
|---|---|---|---|---|
| ៨៧-ព្រះភិក្ខុខន្តិបាលោ | រ៉ុម សារ៉ែន | ឱ្យឡើងទីជា | ព្រះរតនានុបញ្ញា | ព្រះរាជាគណៈកិត្តិយស |
| ៨៨-ព្រះភិក្ខុសីលសំវរោ | សេខ ឧត្តមបញ្ញា | ឱ្យឡើងទីជា | ព្រះចិត្តវិមុត្តិ | ព្រះរាជាគណៈកិត្តិយស |
| ៨៩-ព្រះភិក្ខុវរមុនិ | គង់ វណ្ណា | ឱ្យឡើងទីជា | ព្រះរតនសីលវ័ន្ត | ព្រះរាជាគណៈកិត្តិយស |
| ៩០-ព្រះភិក្ខុញាណពេជោ | ញ៉ុ សាវី | ឱ្យឡើងទីជា | ព្រះសិរីរក្ខិតមុនី | ព្រះរាជាគណៈកិត្តិយស |
| ៩១-ព្រះភិក្ខុពុទ្ធរក្ខិតោ | ញឹល ពុទ្ធី | ឱ្យឡើងទីជា | ព្រះចុល្លវិមុត្តិ | ព្រះរាជាគណៈកិត្តិយស |
| ៩២-ព្រះភិក្ខុខេមឃោសកោ | ឡាយ សុខខុម | ឱ្យឡើងទីជា | ព្រះសោភណាចារ្យ | ព្រះរាជាគណៈកិត្តិយស |
| ៩៣-ព្រះភិក្ខុហិរិសម្បន្នោ | សាន សុខគន្ធា | ឱ្យឡើងទីជា | ព្រះឱវាទមេធា | ព្រះរាជាគណៈកិត្តិយស |
| ៩៤-ព្រះភិក្ខុរក្ខិតសីលោ | ហោ ម៉េងខេង | ឱ្យឡើងទីជា | ព្រះឱវាទសោភ័ណ | ព្រះរាជាគណៈកិត្តិយស |
| ៩៥-ព្រះភិក្ខុយសសុភោ | ជឹម ធុន | ឱ្យឡើងទីជា | ព្រះសតិកោសល | ព្រះរាជាគណៈកិត្តិយស |
| ៩៦-ព្រះភិក្ខុសុវណ្ណជោតោ | ជា សុវណ្ណា | ឱ្យឡើងទីជា | ព្រះសតិកោវិទ | ព្រះរាជាគណៈកិត្តិយស |
| ៩៧-ព្រះភិក្ខុធម្មរក្ខិតោ | ពៅ ស៊ីឡឿន | ឱ្យឡើងទីជា | ព្រះសទ្ធាភិធម្ម | ព្រះរាជាគណៈកិត្តិយស |
| ៩៨-ព្រះភិក្ខុសាវតប្បញ្ញោ | ឆេង សាវរិទ្ធ | ឱ្យឡើងទីជា | ព្រះបញ្ញាភិរ័តន៍ | ព្រះរាជាគណៈកិត្តិយស |
| ៩៩-ព្រះភិក្ខុឥន្ទបញ្ញោ | ឡឿន កុសល | ឱ្យឡើងទីជា | ព្រះសរណាវ័ន្ត | ព្រះរាជាគណៈកិត្តិយស |
| ១០០-ព្រះភិក្ខុធម្មសរណោ | ព្រុំ បណ្ឌិត | ឱ្យឡើងទីជា | ព្រះកោសលកោវិទ | ព្រះរាជាគណៈកិត្តិយស |
| ១០១-ព្រះភិក្ខុសីលវិសុទ្ធោ | ស៊ិន ស៊ា | ឱ្យឡើងទីជា | ព្រះចរណានុលក្ខណ៍ | ព្រះរាជាគណៈកិត្តិយស |
| ១០២-ព្រះភិក្ខុធម្មថេរោ | សាន រស់ | ឱ្យឡើងទីជា | ព្រះសង្ឃានុរ័ក្ខលិខិត | ព្រះរាជាគណៈកិត្តិយស |
| ១០៣-ព្រះភិក្ខុរតនសីលោ | មុំ មាន | ឱ្យឡើងទីជា | ព្រះអភិមេត្តាមុនី | ព្រះរាជាគណៈកិត្តិយស |
| ១០៤-ព្រះភិក្ខុធម្មថេរោ | ម៉ន ឡឿន | ឱ្យឡើងទីជា | ព្រះសុខសរណាមុនី | ព្រះរាជាគណៈកិត្តិយស |
| ១០៥-ព្រះភិក្ខុវីរិយធនោ | សុខ សារិន | ឱ្យឡើងទីជា | ព្រះជោតិវរញ្ញាណ | ព្រះរាជាគណៈកិត្តិយស |
| ១០៦-ព្រះភិក្ខុមេត្តារក្ខិតោ | ធន វិមាន | ឱ្យឡើងទីជា | ព្រះកិត្តិកោសល | ព្រះរាជាគណៈកិត្តិយស |
| ១០៧-ព្រះភិក្ខុរតនធម្មោ | សាយ ទូច | ឱ្យឡើងទីជា | ព្រះខេមសីលវ័ន្ត | ព្រះរាជាគណៈកិត្តិយស |
| ១០៨-ព្រះភិក្ខុជោតបញ្ញោ | សុខ គឹមជាង | ឱ្យឡើងទីជា | ព្រះខេមានុបាល | ព្រះរាជាគណៈកិត្តិយស |
| ១០៩-ព្រះភិក្ខុសុវណ្ណត្ថេរោ | លឹម សុវណ្ណា | ឱ្យឡើងទីជា | ព្រះសុន្ទរសិរីវង្ស | ព្រះរាជាគណៈកិត្តិយស |
| ១១០-ព្រះភិក្ខុធម្មធរោ | ឡាក់ សុភ័ក្រ្ត | ឱ្យឡើងទីជា | ព្រះនាថានុរ័ក្ខ | ព្រះរាជាគណៈកិត្តិយស |
| ១១១-ព្រះភិក្ខុអគ្គសារោ | សាម សុធី | ឱ្យឡើងទីជា | ព្រះយសធម្ម | ព្រះរាជាគណៈកិត្តិយស |
| ១១២-ព្រះភិក្ខុសុមនបញ្ញោ | នាគ សុផានិត | ឱ្យឡើងទីជា | ព្រះសោភ័ណរក្ខិត | ព្រះរាជាគណៈកិត្តិយស |
| ១១៣-ព្រះភិក្ខុជយរក្ខិតោ | កុង ពិសី | ឱ្យឡើងទីជា | ព្រះវិរិយាភិបាល | ព្រះរាជាគណៈកិត្តិយស |
| ១១៤-ព្រះភិក្ខុរតនលាភោ | អ៊ុន សារឿម | ឱ្យឡើងទីជា | ព្រះមេត្តាភិបាលមុនី | ព្រះរាជាគណៈកិត្តិយស |
| ១១៥-ព្រះភិក្ខុឥន្ទសិរី | រស់ សុខា | ឱ្យឡើងទីជា | ព្រះកុសលវ័ន្ត | ព្រះរាជាគណៈកិត្តិយស |
| ១១៦-ព្រះភិក្ខុវុឡ្ហសទ្ធោ | ឆិត្យ សោភ័ណ្ឌ | ឱ្យឡើងទីជា | ព្រះវិចិត្រានុបាល | ព្រះរាជាគណៈកិត្តិយស |
| ១១៧-ព្រះភិក្ខុចន្ទសុទ្ធត្ថេរោ | សាំង សឿន | ឱ្យឡើងទីជា | ព្រះសិរីធម្មលក្ខណ៍ | ព្រះរាជាគណៈកិត្តិយស |
| ១១៨-ព្រះភិក្ខុខន្តិបរមោ | គោគ គឹង | ឱ្យឡើងទីជា | ព្រះញ្ញេយ្យធម្ម | ព្រះរាជាគណៈកិត្តិយស |
| ១១៩-ព្រះភិក្ខុបញ្ញាបទីបោ | ឡេង ធី | ឱ្យឡើងទីជា | ព្រះញ្ញេយ្យកោវិទ | ព្រះរាជាគណៈកិត្តិយស |
| ១២០-ព្រះភិក្ខុវជិរញ្ញាណោ | វង គុន | ឱ្យឡើងទីជា | ព្រះពាកុលវង្ស | ព្រះរាជាគណៈកិត្តិយស |
| ១២១-ព្រះភិក្ខុបរមត្ថធម្មោ | ជីវ ស៊ាងសម្បត្តិ | ឱ្យឡើងទីជា | ព្រះញ្ញេយ្យមុនី | ព្រះរាជាគណៈកិត្តិយស |
| ១២២-ព្រះភិក្ខុព្រហ្មជោតោ | គង់ ផេង | ឱ្យឡើងទីជា | ព្រះញ្ញេយ្យវេទី | ព្រះរាជាគណៈកិត្តិយស |
| ១២៣-ព្រះភិក្ខុជិនវរោ | ព្រឿង ព្រីម | ឱ្យឡើងទីជា | ព្រះញ្ញេយ្យកោសល | ព្រះរាជាគណៈកិត្តិយស |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| | | | |
|---|---|---|---|
| ១២៤-ព្រះភិក្ខុសាសនបណ្ឌិតោ | **មឿន សុទ្ធា** | ឱ្យឡើងទីជា **ព្រះឃោសាធិមុត្តិ** | ព្រះរាជាគណៈកិត្តិយស |
| ១២៥-ព្រះភិក្ខុសច្ចភាណកត្ថរោ | **ស៊ា សាមុទ** | ឱ្យឡើងទីជា **ព្រះសំវរញាណ** | ព្រះរាជាគណៈកិត្តិយស |
| ១២៦-ព្រះភិក្ខុសង្ឃរក្ខិតោ | **ទួន សារិទ្ធ** | ឱ្យឡើងទីជា **ព្រះបញ្ញារតនវិជ្ជា** | ព្រះរាជាគណៈកិត្តិយស |
| ១២៧-ព្រះភិក្ខុធម្មប្បិយោ | **ជុំ សុធី** | ឱ្យឡើងទីជា **ព្រះកិត្តិធម្មបាល** | ព្រះរាជាគណៈកិត្តិយស |
| ១២៨-ព្រះភិក្ខុបិតញ្ញាណោ | **គិត រ័ត្នមុនី** | ឱ្យឡើងទីជា **ព្រះសុមេធធម្មញាណ** | ព្រះរាជាគណៈកិត្តិយស |
| ១២៩-ព្រះភិក្ខុសុជាតោ | **ចាន់ សុខ** | ឱ្យឡើងទីជា **ព្រះមុនីធម្មវង្ស** | ព្រះរាជាគណៈកិត្តិយស |
| ១៣០-ព្រះភិក្ខុចន្ទត្ថេរោ | **ឃិន សុផាត** | ឱ្យឡើងទីជា **ព្រះមេត្តាធម្មគុណ** | ព្រះរាជាគណៈកិត្តិយស |
| ១៣១-ព្រះភិក្ខុរតនរក្ខិតោ | **ឃិន វិចិត្រ** | ឱ្យឡើងទីជា **ព្រះវិចិត្រមុនីសោភ័ណ** | ព្រះរាជាគណៈកិត្តិយស |
| ១៣២-ព្រះភិក្ខុសាសនជោតោ | **ឃួន សាឡុន** | ឱ្យឡើងទីជា **ព្រះវិជ័យវិជ្ជាចារ្យ** | ព្រះរាជាគណៈកិត្តិយស |
| ១៣៣-ព្រះភិក្ខុសច្ចធារី | **សាន កុសល** | ឱ្យឡើងទីជា **ព្រះសច្ចធម្មគិរ័តែ** | ព្រះរាជាគណៈកិត្តិយស |
| ១៣៤-ព្រះភិក្ខុសារានន្ទោ | **ប្រាជ្ញ សាវី** | ឱ្យឡើងទីជា **ព្រះសរណោភិសិរី** | ព្រះរាជាគណៈកិត្តិយស |
| ១៣៥-ព្រះភិក្ខុផលធរោ | **វៃ តុលា** | ឱ្យឡើងទីជា **ព្រះមេត្តាភិរ័ក្ខធម្ម** | ព្រះរាជាគណៈកិត្តិយស |
| ១៣៦-ព្រះភិក្ខុបិតប្បញ្ញោ | **រ៉ាយ ចាន់ហាក់** | ឱ្យឡើងទីជា **ព្រះមេត្តាភិរ័ក្ខវិជ្ជា** | ព្រះរាជាគណៈកិត្តិយស |
| ១៣៧-ព្រះភិក្ខុជយបាលោ | **ឈានរិទ្ធីមណីសត្យា** | ឱ្យឡើងទីជា **ព្រះពាក្យលវិជ័យ** | ព្រះរាជាគណៈកិត្តិយស |
| ១៣៨-ព្រះភិក្ខុធនវឌ្ឍនោ | **សន វ៉ាត់រ៉ាត់ប៊ុនធឿន** | ឱ្យឡើងទីជា **ព្រះខេមរានុបាល** | ព្រះរាជាគណៈកិត្តិយស |

**មាត្រា២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នស/រកត.១២២១.១៤៩៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០២១*

នរោត្តមសីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៩១ អនក្រ.បក

# អនុក្រឹត្យ

**ស្តីពី**

**ការធ្វើអនុប្បយោគផ្ទៃដីទំហំ ១ ១៥៤ (មួយពាន់មួយរយហាសិបបួន)ហិកតា ស្ថិតនៅក្នុងឧទ្យានជាតិបូទុមសាគរ ភូមិសាស្ត្រ ឃុំតានួន ស្រុកបូទុមសាគរ ខេត្តកោះកុង ជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បីដោះស្រាយជូនប្រជាពលរដ្ឋដែលប៉ះពាល់ជាមួយក្រុមហ៊ុន Union Development Group Co.,Ltd. និងត្រៀមបម្រុងទុកសម្រាប់អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស0/រកត/៣២០/៤២១ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការកំណត់តំបន់ការពារធម្មជាតិ

- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០១ /១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- យោងលិខិតលេខ ១០៥៤ សណ.បស្ថ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ របស់ក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ ._**

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំ ១ ១៥៤ (មួយពាន់មួយរយហាសិបបួន)ហិកតា ស្ថិតនៅក្នុងឧទ្យានជាតិបុទុមសាគរ ភូមិសាស្ត្រ ឃុំតានួន ស្រុកបូទុមសាគរ ខេត្តកោះកុង ជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បីដោះស្រាយជូនប្រជាពលរដ្ឋរងផលប៉ះពាល់ជាមួយក្រុមហ៊ុន Union Development Group Co., Ltd. និងត្រៀមបម្រុងទុកសម្រាប់អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចជូនដល់ប្រជាពលរដ្ឋដែលគ្មានដីធ្លី ឬខ្វះខាតដីពិតប្រាកដសម្រាប់សាងសង់លំនៅឋាន និងដាំដំណាំលក្ខណៈគ្រួសារ ព្រមទាំងរៀបចំហេដ្ឋារចនាសម្ព័ន្ធ ដែលមានផែនទី និងចំណុចនិយាមកាភ្ជាប់នៃលិខិតលេខ ១០៥៤ សណ.បស្ថ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ របស់ក្រសួងបរិស្ថាន ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២._**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកោះកុង ក្នុងការស្នើសុំចុះបញ្ជីជាដីឯកជនរបស់រដ្ឋ ដើម្បីដោះស្រាយជូនប្រជាពលរដ្ឋរងផលប៉ះពាល់ជាមួយក្រុមហ៊ុន Union Development Group Co., Ltd. និងត្រៀមបម្រុងទុកសម្រាប់អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចជូនដល់ប្រជាពលរដ្ឋដែលគ្មានដីធ្លី ឬ ខ្វះខាតដីពិតប្រាកដ សម្រាប់សាងសង់លំនៅឋាន និងដាំដំណាំលក្ខណៈគ្រួសារ ព្រមទាំងរៀបចំហេដ្ឋារចនាសម្ព័ន្ធ។

**មាត្រា៣._**

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកោះកុង ត្រូវរៀបចំបោះបង្គោលព្រំដី ដែលបានធ្វើអនុបយោគដូចមានចែងក្នុងមាត្រា១ នៃអនុក្រឹត្យនេះ និងអនុវត្តការចុះបញ្ជីដី រួចលើកសំណើសុំផ្តល់សិទ្ធិលើក្បាលដីតាមគោលការណ៍ និងនីតិវិធីជាធរមាន។

**មាត្រា៤._**

ក្រសួងបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីគ្រប់គ្រងផ្ទៃដីតំបន់ការពារធម្មជាតិឡើងវិញក្នុងភូមិសាស្ត្រ ឃុំតានួន ស្រុកបូទុមសាគរ ខេត្តកោះកុងដោយសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកោះកុង ឱ្យស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា៥._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៦._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកោះកុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៧រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៩៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា១.** បំពាក់មេដាយ**មុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជនចំនួន ៣៥រូប ដែលបានចូលរួមជួយកសាងសមិទ្ធផលនានា នៅវត្តព្រីក្សានិងវត្តសំរោងវ័ត្ត ឃុំពេជសារ ស្រុកកោះអណ្តែត ខេត្តតាកែវ កន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ**មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ**

១- ឯកឧត្តម យុន សារឿន អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
២- លោក ជិន ដេវីត សប្បុរសជនរាជធានីភ្នំពេញ

ខ-មេដាយ**មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា**

១- ឯកឧត្តម ជុន វាសនា ជំនួយការផ្ទាល់សម្តេចក្រឡាហោម ស ខេង
២- លោក ជួង វ៉ាន ប្រធានមន្ទីរធម្មការ និង សាសនាខេត្តតាកែវ
៣- វរសេនីយ៍ឯក ឆាំ ប៊ុនធឿន ស្នងការរងនៃស្នងការដ្ឋាននគរបាលខេត្តកណ្តាល
៤- លោក គិន ភក្តី អភិបាលនៃគណៈអភិបាលស្រុកកោះអណ្តែត

| | | | |
|---|---|---|---|
| ៥- | លោក | ផាន់ វ៉ាន់ | អនុប្រធានមន្ទីរសុខាភិបាលខេត្តតាកែវ |
| ៦- | ឧបាសិកា | ជា ស៊ីន | សប្បុរជននៅរាជធានីភ្នំពេញ |
| ៧- | អ្នកស្រី | សំ គឹមលី | សប្បុរជននៅរាជធានីភ្នំពេញ |
| ៨- | លោក | ហង់ សែន | សប្បុរជននៅរាជធានីភ្នំពេញ |
| ៩- | លោក | ង៉ែត គីម | សប្បុរជននៅរាជធានីភ្នំពេញ |
| ១០- | លោក | ងិន មករា | សប្បុរជននៅរាជធានីភ្នំពេញ |
| ១១- | អ្នកស្រី | ម៉ន សុខនី | សប្បុរជននៅរាជធានីភ្នំពេញ |
| ១២- | លោក | គួយ ណារិន | សប្បុរជននៅរាជធានីភ្នំពេញ |
| ១៣- | លោក | យន់ នោរ៉ា | សប្បុរសជនរាជធានីភ្នំពេញ |
| ១៤- | លោក | សៀ វេងគៀង | សប្បុរសជនរាជធានីភ្នំពេញ |
| ១៥- | លោក | ងន់ ចាន់សារ៉េន | សប្បុរជននៅរាជធានីភ្នំពេញ |
| ១៦- | លោក | ផាង ពិសិដ្ឋ | សប្បុរជននៅរាជធានីភ្នំពេញ |
| ១៧- | លោក | សៀង លី | សប្បុរជននៅរាជធានីភ្នំពេញ |
| ១៨- | លោក | ភាព លីហុង | សប្បុរជននៅរាជធានីភ្នំពេញ |
| ១៩- | លោក | ប៉ែន ចាន់ប៊ិច | សប្បុរជននៅរាជធានីភ្នំពេញ |
| ២០- | លោក | ង៉ែត គា | សប្បុរជននៅរាជធានីភ្នំពេញ |
| ២១- | លោក | តាក សារិទ្ធិ | សប្បុរជននៅរាជធានីភ្នំពេញ |
| ២២- | អ្នកស្រី | វ៉េត ម៉ារ៉ា | សប្បុរជននៅខេត្តតាកែវ |

គ-មេដាយ**មុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ**

| | | | |
|---|---|---|---|
| ១- | លោក | នាង សុខឃីម | សប្បុរជននៅរាជធានីភ្នំពេញ |
| ២- | លោក | រី វណ្ណា | សប្បុរជននៅរាជធានីភ្នំពេញ |
| ៣- | លោក | រ៉ិត ណាង | សប្បុរជននៅរាជធានីភ្នំពេញ |
| ៤- | លោក | គឹម តុលា | សប្បុរជននៅរាជធានីភ្នំពេញ |
| ៥- | លោក | ផាង ហ៊ល | មេឃុំពេជសារ |
| ៦- | លោក | ឈុំ ពិសិដ្ឋ | សប្បុរជននៅរាជធានីភ្នំពេញ |
| ៧- | លោក | ឃុន សាវ៉ូន | សប្បុរជននៅរាជធានីភ្នំពេញ |
| ៨- | អ្នកស្រី | ហៀប សុផានី | សប្បុរជននៅរាជធានីភ្នំពេញ |
| ៩- | លោក | គង់ ប៊ុណ្ណា | សប្បុរជននៅរាជធានីភ្នំពេញ |
| ១០- | លោក | ព្រំ ថុល | សប្បុរជននៅរាជធានីភ្នំពេញ |

១១- លោក ហ៊ិន ចាន់ធា សប្បុរសជននៅរាជធានីភ្នំពេញ

**មាត្រា២.**.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា អភិបាលនៃគណៈអភិបាលខេត្តតាកែវ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..១.៥៣..............សហវ [illegible]

# ប្រកាស
## ស្តីពី
## វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញក្រឹត្យ-ច្បាប់លេខ ២២ ក្រ.ច ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៨៥ ស្តីពីពន្ធប៉ាតង់
- បានឃើញព្រះរាជក្រមលេខ ១១ ន.ស ៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone : (+855)23 890 666

- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៩៨ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការកែសម្រួលវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងកំណត់វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់លើសកម្មភាពអាជីវកម្មរបស់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដើម្បីគ្រប់គ្រងនិងប្រមូលចំណូលពន្ធឱ្យមានប្រសិទ្ធភាពស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.- កម្មវត្ថុនៃពន្ធ**

ពន្ធប៉ាតង់ គឺជាពន្ធប្រចាំឆ្នាំដែលត្រូវបានកំណត់លើសកម្មភាពអាជីវកម្មដោយផ្អែកលើប្រភេទអ្នកជាប់ពន្ធ និងកម្រិតផលរបរ។

**ប្រការ ៤.- បែបបទនៃការបង់ពន្ធ**

បែបបទនៃការបង់ពន្ធប៉ាតង់ ត្រូវបានកំណត់ដូចខាងក្រោម÷

១- អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មច្រើន ត្រូវបង់ពន្ធប៉ាតង់ផ្សេងគ្នាទៅតាមសកម្មភាពអាជីវកម្មនីមួយៗ។

ឧទាហរណ៍÷ អ្នកជាប់ពន្ធម្នាក់ដែលមានសកម្មភាពអាជីវកម្មនីហរ័ណ-អាហរ័ណ ដឹកជញ្ជូន និងសណ្ឋាគារ ត្រូវបង់ពន្ធប៉ាតង់សម្រាប់ ៣ សកម្មភាពអាជីវកម្មផ្សេងគ្នា។

២- សកម្មភាពជាឧបសម្ព័ន្ធនានានៃសកម្មភាពអាជីវកម្មត្រូវបានចាត់ទុកថាជាសកម្មភាពអាជីវកម្មតែមួយ។

ឧទាហរណ៍ទី១÷ សណ្ឋាគារមួយដែលមានក្លឹបកម្សាន្ត ភោជនីយដ្ឋាន កន្លែងម៉ាស្សា ក្លឹបហាត់ប្រាណ ឬសកម្មភាពដទៃដែលជាឧបសម្ព័ន្ធនៃសកម្មភាពសណ្ឋាគារដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់អ្នកជាប់ពន្ធតែមួយ និងស្ថិតក្នុងទីតាំងរួមជាមួយសណ្ឋាគារ ត្រូវបង់ពន្ធប៉ាតង់តែមួយ។

ឧទាហរណ៍ទី២÷ សហគ្រាសមួយប្រកបអាជីវកម្ម ទិញ-លក់កុំព្យូទ័រ កម្មវិធីកុំព្យូទ័រ ឧបករណ៍លេងហ្គេមទូរស័ព្ទដៃ ឧបករណ៍ទូរគមនាគមន៍ផ្សេងៗ វិទ្យុ ទូរទស្សន៍ ម៉ាស៊ីនចាក់និងថតស៊ីឌី ឌីវីឌី ឧបករណ៍បំពងសំឡេង ដែលអាជីវកម្មនេះស្ថិតនៅក្នុងចង្កោមសកម្មភាពអាជីវកម្ម "ទិញ-លក់កុំព្យូទ័រនិងឧបករណ៍អេឡិចត្រូនិក" តែមួយ ហើយស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អ្នកជាប់ពន្ធតែមួយ និងស្ថិតក្នុងទីតាំងប្រកបអាជីវកម្មតែមួយ ត្រូវបង់ពន្ធប៉ាតង់តែមួយ។

៣- អ្នកជាប់ពន្ធដែលមានទីកន្លែងអាជីវកម្មជាគោលដើម ទីចាត់ការសហគ្រាស សាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់សកម្មភាពអាជីវកម្មតែមួយនៅក្នុងរាជធានី-ខេត្តតែមួយ ត្រូវបង់ពន្ធប៉ាតង់តែមួយ។

៤- អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មនៅក្នុងរាជធានី-ខេត្តផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់ទៅតាមរាជធានី-ខេត្តដែលអាជីវកម្មនោះស្ថិតនៅ។

**ប្រការ ៥.. កម្រិតប្រាក់ពន្ធប៉ាតង់ត្រូវបង់**

ប្រាក់ពន្ធប៉ាតង់ត្រូវបានកំណត់ដូចខាងក្រោម÷

១- អ្នកជាប់ពន្ធតូច ត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ៤០០ ០០០ រៀល។

២- អ្នកជាប់ពន្ធមធ្យម ត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ១ ២០០ ០០០ រៀល។

៣- អ្នកជាប់ពន្ធធំ ត្រូវបង់÷

ក- ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ៣ ០០០ ០០០ រៀល។

ខ- ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ៥ ០០០ ០០០ រៀល ក្នុងករណីដែលមានផលរបរលើសពី ១០ ០០០ លានរៀល។

អ្នកជាប់ពន្ធដែលមានទីកន្លែងអាជីវកម្មជាគោលដើម ទីចាត់ការសហគ្រាស សាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់សកម្មភាពអាជីវកម្មតែមួយដែលស្ថិតនៅតាមរាជធានី-ខេត្តផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់អប្បបរមាសម្រាប់ប្រភេទអ្នកជាប់ពន្ធនីមួយៗទៅតាមរាជធានី-ខេត្តដែលអាជីវកម្មនោះស្ថិតនៅ។

**ប្រការ ៦.. កាលបរិច្ឆេទបង់ពន្ធ**

ពន្ធប៉ាតង់ ត្រូវបង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ។ ពន្ធប៉ាតង់ត្រូវបង់នៅរដ្ឋបាលសារពើពន្ធដែលអ្នកជាប់ពន្ធមានទីកន្លែងប្រកបអាជីវកម្មពិតប្រាកដ។

អ្នកជាប់ពន្ធដែលចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល ៦ខែដើមឆ្នាំ ត្រូវបង់ប្រាក់ពន្ធប៉ាតង់ពេញមួយឆ្នាំ ប៉ុន្តែប្រសិនបើចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល ៦ខែចុងឆ្នាំ អ្នកជាប់ពន្ធត្រូវបង់ប្រាក់ពន្ធប៉ាតង់ពាក់កណ្តាល។

**ប្រការ ៧.. ប័ណ្ណពន្ធប៉ាតង់**

ប័ណ្ណពន្ធប៉ាតង់ មានតម្លៃតែចំពោះអ្នកជាប់ពន្ធដែលមានឈ្មោះក្នុងប័ណ្ណពន្ធប៉ាតង់តែប៉ុណ្ណោះ។ ករណីមានការផ្លាស់ប្តូរទីកន្លែងទៅរាជធានី-ខេត្តផ្សេង ឬផ្លាស់ប្តូរមុខរបរអាជីវកម្មថ្មី ត្រូវបង់ប្រាក់ពន្ធប៉ាតង់ថ្មីម្តងទៀត។

ក្នុងការចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងថ្លៃក្នុងការផ្គត់ផ្គង់ទំនិញឬសេវា អ្នកជាប់ពន្ធត្រូវមានប័ណ្ណពន្ធប៉ាតង់ដែលបញ្ជាក់ពីសកម្មភាពអាជីវកម្មរបស់ខ្លួនស្របតាមកម្មវត្ថុនៃការដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងថ្លៃក្នុងការផ្គត់ផ្គង់ទំនិញឬសេវាទាំងនោះ។

អ្នកជាប់ពន្ធ ត្រូវមានកាតព្វកិច្ចដាក់តាំងបង្ហាញប័ណ្ណពន្ធប៉ាតង់ដែលមានសុពលភាពនៅតាមទីតាំងប្រកបអាជីវកម្មរបស់ខ្លួន។ ក្នុងករណីអ្នកជាប់ពន្ធមិនបានដាក់តាំងបង្ហាញប័ណ្ណពន្ធប៉ាតង់ ត្រូវចាត់ទុកថាបានប្រព្រឹត្តអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ស្របតាមមាត្រា ១២៨ និងមាត្រា ១៣៣ នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ ៨.- ការឈប់ ផ្អាក ឬផ្លាស់ប្តូរម្ចាស់អាជីវកម្ម**

១- សហគ្រាសដែលស្នើសុំឈប់ឬផ្អាកអាជីវកម្ម នៅក្នុងឆ្នាំជាប់ពន្ធណាមួយ÷

ក- តម្រូវឱ្យបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចរន្តពាក់កណ្តាល ប្រសិនបើដាក់ពាក្យសុំឈប់ ឬផ្អាកអាជីវកម្មនៅក្នុងអំឡុង ៦ខែដើមឆ្នាំនៃឆ្នាំចរន្ត។

ខ- តម្រូវឱ្យបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចរន្តពេញមួយឆ្នាំ ប្រសិនបើដាក់ពាក្យសុំឈប់ ឬផ្អាកអាជីវកម្មនៅក្នុងអំឡុង ៦ខែចុងឆ្នាំនៃឆ្នាំចរន្ត។

ប្រាក់ពន្ធប៉ាតង់ដែលបានបង់រួចហើយ មិនត្រូវបានបង្វិលសងវិញទេ។

២-ចំពោះអាជីវកម្មដែលផ្លាស់ប្តូរម្ចាស់ បើម្ចាស់ចាស់បានបង់ពន្ធប៉ាតង់ហើយ ម្ចាស់ថ្មីមិនបាច់បង់ពន្ធប៉ាតង់ជាថ្មីទៀតទេ ប្រសិនបើមានគ្រប់លក្ខណៈពីរខាងក្រោមនេះ÷

ក- មិនផ្លាស់ប្តូរសកម្មភាពអាជីវកម្ម។

ខ- ម្ចាស់ថ្មីជាឪពុក ម្តាយ ប្តី ប្រពន្ធ កូន ឬអ្នកស្នងស្របច្បាប់របស់ម្ចាស់អាជីវកម្មចាស់។

**ប្រការ ៩.- និរាករណ៍**

ប្រកាសលេខ ១៩៨ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការកែសម្រួលវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ ត្រូវទុកជានិរាករណ៍។

**ប្រការ ១០.- ការអនុវត្ត**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៣កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចប្រការ ១០ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ [illegible]......សហវ.[illegible]

# ប្រកាស

## ស្តីពី

## វិធាននិងនីតិវិធីនៃការព្យួរការបំពេញបែបបទបញ្ចេញទំនិញពីគយចំពោះទំនិញនាំចេញ-នាំចូលល្មើសកម្មសិទ្ធិបញ្ញា

## ឧបនាយករដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែល ប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៤/០០៦ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការអនុវត្តច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៤៧ សហវ.ប្រក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងពង្រឹងប្រសិទ្ធភាព នៃការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញាតាមរយៈការកំណត់វិធាន និងនីតិវិធីសម្រាប់ព្យួរការបំពេញបែបបទបញ្ចេញទំនិញពីគយនូវរាល់ការនាំចេញ- នាំចូលទំនិញដែលល្មើសច្បាប់ពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញានៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការព្យួរការបំពេញបែបបទបញ្ចេញទំនិញពីគយចំពោះទំនិញនាំចេញ- នាំចូលល្មើសកម្មសិទ្ធិបញ្ញា ដែលពាក់ព័ន្ធនឹងម៉ាក ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។

## ជំពូកទី ២
## ការស្នើសុំព្យួរការបំពេញបែបបទបញ្ចេញទំនិញពីគយលើទំនិញសង្ស័យល្មើសកម្មសិទ្ធិបញ្ញា

**ប្រការ ៣.-**

ម្ចាស់កម្មសិទ្ធិបញ្ញាដែលបានចុះបញ្ជីស្របច្បាប់ ឬភ្នាក់ងារតំណាងស្របច្បាប់ អាចដាក់ពាក្យស្នើសុំទៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឱ្យផ្អាកជាបណ្តោះអាសន្ននូវការបំពេញបែបបទបញ្ចេញទំនិញពីគយលើទំនិញសង្ស័យថាល្មើសកម្មសិទ្ធិបញ្ញាពាក់ព័ន្ធនឹងម៉ាក ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែលដោយបំពេញពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

អ្នកដាក់ពាក្យស្នើសុំព្យួរការបំពេញបែបបទបញ្ចេញទំនិញពីគយបណ្តោះអាសន្នចំពោះទំនិញដូចខាងលើ ត្រូវបង់កម្រៃចំនួន ១,០០០,០០០ រៀល (មួយលានរៀលគត់)។

**ប្រការ ៤.-**

អ្នកដាក់ពាក្យស្នើសុំព្យួរការបំពេញបែបបទបញ្ចេញទំនិញពីគយបណ្ដោះអាសន្នចំពោះទំនិញដែលសង្ស័យល្មើសកម្មសិទ្ធិបញ្ញា ត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារដូចខាងក្រោម៖

ក. ច្បាប់ចម្លងនៃវិញ្ញាបនបត្រចុះបញ្ជីម៉ាក ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

ខ. ការរៀបរាប់ដ៏ល្អិតល្អន់ពីទំនិញដែលម៉ាករបស់វាត្រូវបានប្រើប្រាស់ ព្រមទាំងទំនិញគំរូដែលបានចុះបញ្ជីស្របច្បាប់ ប្រសិនបើមានសំណូមពរ

គ. លិខិតថ្លែងបញ្ជាក់ពីហេតុផលជាមូលដ្ឋាន និងភស្តុតាងជាក់ស្ដែងថាទំនិញទាំងនោះល្មើសកម្មសិទ្ធិបញ្ញា

ឃ. ឯកសារបញ្ជាក់លក្ខណៈពិសេសដែលអាចវិនិច្ឆ័យភាពខុសគ្នារវាងទំនិញពិត និងក្លែងក្លាយ

ង. លិខិតបញ្ជាក់អត្តសញ្ញាណ ដូចជាអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន

ច. លិខិតផ្ទេរសិទ្ធិពីម្ចាស់កម្មសិទ្ធិបញ្ញា ប្រសិនបើពាក្យស្នើសុំនោះត្រូវបានដាក់ដោយតំណាងដែលទទួលសិទ្ធិ

ឆ. បង់កម្រៃរដ្ឋបាលដូចក្នុងកថាខណ្ឌ ២ នៃប្រការ ៣។

**ប្រការ ៥.-**

ក្នុងអំឡុងពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំដូចក្នុងប្រការ ៤ នៃប្រកាសនេះ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរថាទទួលយកទៅចាត់ការ ឬបដិសេធនូវសំណើសុំនេះ។

**ប្រការ ៦ .-**

ក្នុងរយៈពេលមិនលើសពី ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីការឆ្លើយតបទៅម្ចាស់កម្មសិទ្ធិបញ្ញា ឬតំណាងពីការទទួលយកការស្នើសុំព្យួរការបំពេញបែបបទបញ្ចេញទំនិញពីគយទៅចាត់ការ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវជូនព័ត៌មានទៅម្ចាស់ទំនិញអំពីការព្យួរការបំពេញបែបបទបញ្ចេញទំនិញពីគយរួមទាំងឈ្មោះ និងអាសយដ្ឋាននៃអ្នកស្នើសុំព្យួរ និងត្រូវអញ្ជើញម្ចាស់ទំនិញឬតំណាង និងម្ចាស់កម្មសិទ្ធិបញ្ញាឬតំណាង ដើម្បីចូលរួមត្រួតពិនិត្យរូបវន្តទំនិញ ដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទត្រួតពិនិត្យរូបវន្តទំនិញ។ ក្នុងរយៈពេលមិនលើសពី ១០ (ដប់)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបាននូវការអញ្ជើញម្ចាស់ទំនិញឬតំណាង និងម្ចាស់កម្មសិទ្ធិបញ្ញាឬតំណាង ត្រូវបញ្ជាក់ជាលាយលក្ខណ៍អក្សរពីការចូលរួមត្រួតពិនិត្យរូបវន្តទំនិញនេះ មកអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាវិញ។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា ១៥-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ**
**បច្ចេកវិទ្យា និងនវានុវត្តន៍**
**រដ្ឋលេខាធិការ**

**មាន សុគា**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលារាជធានីភ្នំពេញ
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ
-រដ្ឋបាលខណ្ឌកំបូល
-រដ្ឋបាលសង្កាត់កំបូល
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation Religion King

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
Ministry of Industry, Science, Technology & Innovation

លេខ:.................................... ថ្ងៃ.................... ខែ.............. ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.០៤.... ខែ.............. ឆ្នាំ២០២១

# ប្រកាសបង្កើតសាខារោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ១៥៨៩/២១ គ.វ.ក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២១ ស្ដីពីការពង្រីកបន្ថែមអគារផលិតកម្មរោងចក្រកាត់ដេរសម្លៀកបំពាក់ នៅលើទីតាំងថ្មី របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតសាខារោងចក្រកាត់ដេរសម្លៀកបំពាក់ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១ របស់ក្រុមហ៊ុនអូសិន អីកែរីល មេនូហ្វេកធីរីង ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន អូសិន អីកែរីល មេនូហ្វេកធីរីង ឯ.ក **(OCEAN APPAREL MANUFACTURING CO., LTD)** តំណាងដោយលោក **LU, CHIEN-TUNG** សញ្ជាតិចិន(តៃវ៉ាន់) កាន់លិខិតឆ្លងដែនលេខ 352053382 ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៩ បង្កើតសាខារោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ ភូមិត្រពាំងទួល សង្កាត់កំបូល ខណ្ឌកំបូល រាជធានីភ្នំពេញ។

៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
| --- | --- |
| សម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រកាត់ដេរសម្លៀកបំពាក់ អូសិន អ៊ីតែរីល មេនូហ្វេកធឺរីង ឯ.ក** (សាខាទី១) "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ**
**បច្ចេកវិទ្យា និងនវានុវត្តន៍**
**រដ្ឋលេខាធិការ**

**មាន សុភា**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលារាជធានីភ្នំពេញ
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ
-រដ្ឋបាលខណ្ឌកំបូល
-រដ្ឋបាលសង្កាត់កំបូល
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation Religion King

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
Ministry of Industry, Science, Technology & Innovation

លេខ: ៣៩៦ ........................

ថ្ងៃ...................... ខែ.................. ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី......១៥...... ខែ.................. ឆ្នាំ២០២១

# ប្រកាសបង្កើតសាខារោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតខណ្ឌកំបូល នៃរាជធានីភ្នំពេញ
- យោងលិខិតលេខ០២៣៩/២០ ក.ត.ស.ព ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ ស្តីពីការពង្រីកផលិតកម្មលើទីតាំងថ្មី របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតសាខារោងចក្រផលិតខ្សែភ្លើងគ្រឿងបង្គុំអេឡិចត្រូនិចសម្រាប់រថយន្ត ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ របស់ក្រុមហ៊ុន ស៊ុមី (ខេមបូឌា) វ៉ាយរីង ស៊ីស្ទឹម

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ស៊ុមី (ខេមបូឌា) វ៉ាយរីង ស៊ីស្ទឹម (**SUMI (CAMBODIA) WIRING SYSTEMS CO., LTD.**) តំណាងដោយលោក **MOCHIDA SHIGERU** សញ្ជាតិជប៉ុន កាន់លិខិតឆ្លងដែនលេខTZ1108944 ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦ បង្កើតសាខារោងចក្រផលិតខ្សែភ្លើងគ្រឿងបង្គុំអេឡិចត្រូនិចសម្រាប់រថយន្ត ដែលមានទីតាំងស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (ដីឡូត៍លេខP1-017, P1-018, P1019 សង្កាត់កន្ទោក សង្កាត់ភ្លើងឆេះរទេះ និងសង្កាត់បឹងធំ ខណ្ឌកំបូល រាជធានីភ្នំពេញ)។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
| --- | --- |
| ខ្សែភ្លើងគ្រឿងបង្គុំអេឡិចត្រូនិច | ២៦១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្ដីណែនាំស្ដីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖" **រោងចក្រផលិតខ្សែភ្លើងគ្រឿងបង្គុំអេឡិចត្រូនិចសម្រាប់រថយន្ត ស៊ុមី (ខេមបូឌា) វ៉ាយរីង ស៊ីស្ទឹម** " (សាខាទី១)

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្ដូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្ដូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្ដូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្ដាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពី វិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់ហើសអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការ របស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ**
**បច្ចេកវិទ្យា និងនវានុវត្តន៍**
**រដ្ឋលេខាធិការ**

**មាន សុគា**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលារាជធានីភ្នំពេញ
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ
-អង្គភាពរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ
-រដ្ឋបាលខណ្ឌកំបូល
-រដ្ឋបាលសង្កាត់កន្ទោក សង្កាត់ក្លើងធេះវេទៈ និងសង្កាត់បឹងធំ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០៧៤៧ រថ.អប្រក.ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ

លេខ ០៧៤៧ រថ.អប្រក.លអ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ របស់លោកស្រី មាស សុខេម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្ដល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈមានស្លាកយីហោឈ្មោះ **ដេប៉ូតេលា ភូមិស្ទឹងចាស់** ស្ថិតនៅភូមិស្ទឹងចាស់ ឃុំតយម៉េង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ របស់លោកស្រី មាស សុខេម (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរខេត្តបន្ទាយមានជ័យ
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើ ឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានបន្ទប់ស្នាក់នៅក្នុងបរិវេណស្ថានីយ

២. មិនអនុញ្ញាតឱ្យមានការស្តុកទុក និងចែកចាយប្រេងឥន្ធនៈតាមបីដុងជ័រ និងលក់សាំងដបក្នុងទីធ្លាស្ថានីយ

៣. មិនអនុញ្ញាតឱ្យមានការតាំងលក់ឥវ៉ាន់ក្នុងបរិវេណស្ថានីយដោយគ្មានសណ្ដាប់ធ្នាប់

៤. ទីតាំងអាងដាក់ពោងប្រេងឥន្ធនៈកប់ដីត្រូវស្ថិតនៅចម្ងាយអប្បបរមា ១ ម៉ែត្រពីគ្រឹះសំណង់



៥៧

៥. ពោងប្រេងឥន្ធនៈមួយដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ
៦. បំពង់ខ្យល់ប្រេងឥន្ធនៈមិនត្រូវមានបំពាក់វ៉ាន់បិទបើក
៧. ត្រូវរៀបចំឱ្យមានកបំពង់ទទួលប្រេងឥន្ធនៈពីរថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ
៨. ទូចាក់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ ម៉ែត្រ ឃ្លាតពីអគារការិយាល័យ
៩. ត្រូវមានគន្លឹះអាសន្នរួម
១០. ទុយោចាក់ប្រេងមិនត្រូវមានប្រវែងលើសពី ៦ ម៉ែត្រ
១១. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក
១២. ត្រូវរៀបចំផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ
១៣. ត្រូវគូសគំនូសសញ្ញាសម្រាប់ចំណតរថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០៧៤៧.រ៉ែ.អបក.លអ........ចុះថ្ងៃទី.........២៧........ខែ...ធ្នូ..........ឆ្នាំ២០២០...............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០៧៤៧.រ៉ែ.អបក.លអ ចុះថ្ងៃទី....២៧.....ខែ...ធ្នូ............ឆ្នាំ២០២០....នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពល ខេត្តបន្ទាយមានជ័យ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ...៨កើត.ខែ.....បុស្ស...ឆ្នាំជូត..ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.២៧..ខែ...ធ្នូ.....ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ-សែម**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តបន្ទាយមានជ័យ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០៧៤៨ រ៉ែ.អប.ប្រក.ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ

លេខ ០៧៤៨ រ៉ែ.អប.ប្រក.លអ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០២០

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០២០ របស់លោកស្រី គង់ ឡៃហៀក
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈដែលមានស្លាកយីហោ ដេប៉ូតេលា គង់ សុខកាំង ស្ថិតនៅភូមិសុក្រំជ្រុំ ឃុំគងជ័យ ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ របស់លោកស្រី គង់ ឡៃហៀក (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានលំនៅដ្ឋានក្នុងទីធ្លាស្ថានីយ

២. មិនអនុញ្ញាតឱ្យមានការដាក់លក់ចែកចាយហ្គាសក្នុងធុង

៣. ទីធ្លាស្ថានីយត្រូវតែស្រឡះ និងស្អាតជានិច្ច

៤. ពោងប្រេងឥន្ធនៈគ្រប់ប្រភេទត្រូវកប់ក្រោមដីទាំងអស់

៥. ពោងប្រេងឥន្ធនៈមួយដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ
៦. ត្រូវរៀបចំឱ្យមានកបំពង់ទទួលប្រេងឥន្ធនៈ
៧. បំពង់ខ្យល់ត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ ម៉ែត្រពីលំនៅដ្ឋាន
៨. ទូចាក់ឧស្ម័នឥន្ធនៈស្ថិតនៅចម្ងាយអប្បបរមា ៧ ម៉ែត្រពីទូចាក់ប្រេងឥន្ធនៈ
៩. ត្រូវមានបំពាក់វ៉ានបិទ បើក នៅជាប់នឹងគួបំពង់ខ្យល់
១០. ត្រូវគូសគំនូសសញ្ញាសម្រាប់ចំណតរថយន្តស៊ីទែនផ្ទេរប្រេង និងឧស្ម័នឥន្ធនៈ
១១. ត្រូវរៀបចំស្លាកសញ្ញាបម្រាមស្ដីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់
១២. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាស នៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន អំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ០៧៤៨/២០.អបក.លអ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ០៧៤៨/២០.អបក.លអ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពល ខេត្តត្បូងឃ្មុំ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ៨កើត ខែមុសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តត្បូងឃ្មុំ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០៧៤៩ រថ.អប្រក.ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
## លេខ០៧៤៩ រថ.អប្រក.លអ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០២០

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយល្បាយប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ របស់លោក ធន សុធា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ មានស្លាកយីហោ ដេប៉ូតេលា ធន សុធា ស្ថិតនៅភូមិត្រពាំងខ្នារ ឃុំស្វាយលើ ស្រុកស្វាយលើ ខេត្តសៀមរាប របស់លោក ធន សុធា (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមប្រកាសលេខ ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែ និងថាមពលដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

១. លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី

២. លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែ និងថាមពលដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានលំនៅដ្ឋានក្នុងបរិវេណស្ថានីយ

២. ត្រូវមានកបំពង់ទទួលប្រេងឥន្ធនៈពីរថយន្តផ្ទេរប្រេងឥន្ធនៈ

៣. ពោងសម្រាប់ដាក់ប្រេងឥន្ធនៈគ្រប់ប្រភេទនៅក្នុងស្ថានីយត្រូវកប់ក្រោមដីទាំងអស់

៤. អាងដាក់ពោងប្រេងឥន្ធនៈ ត្រូវស្ថិតនៅចម្ងាយអប្បបរមា ២,៥០ម៉ែត្រ ពីព្រំដីស្ថានីយ

៥. ពោងប្រេងឥន្ធនៈមួយដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ



៩៨

៦. ទូចាក់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយ ៦ម៉ែត្រ ពីរបងព្រំដីស្ថានីយ

៧. ទូចាក់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ម៉ែត្រពីអគារការិយាល័យ

៨. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ម៉ែត្រ ពីរបងព្រំដីស្ថានីយ

៩. ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក

១០. ត្រូវមានផ្ទាំងព័ត៌មាន និងស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែនិងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ០៧៤៩ រ៉ែ.អបក.ល.អ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០២០ របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈ ពេល១២(ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ...០៧៤ ទ.ស.ក :អ.ព.ក.ទ.ប.ក... ថ្ងៃទី...២៦...ខែ...វិច្ឆិកា...ឆ្នាំ២០២០...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយក នៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលខេត្តសៀមរាប និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែ...មិគសិរ...ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...២៦...ខែ...វិច្ឆិកា...ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តសៀមរាប
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ០៧៥០ រ៉ែ.អធិក.ប្រក.

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ
## លេខ០៧៥០រ៉ែ.អធិក.លអ.....ចុះថ្ងៃទី.....២២.....ខែ.....ធ្នូ.....ឆ្នាំ ២០២០.

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- បានឃើញប្រកាសលេខ ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសារាចរលេខ ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ របស់លោកស្រី រ៉ូ រ៉ានី
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ យីហោ ដេប៉ូតេលា ហុក ស្រីនី ស្ថិតនៅភូមិកំប៉ូវ ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង របស់លោកស្រី រ៉ូ រ៉ានី (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

១. លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី

២. លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមសារាចរលេខ ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ នូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. ត្រូវមានកបំពង់ទទួលប្រេងឥន្ធនៈ
២. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ម៉ែត្រ ពីរបងព្រំដី
៣. មិនអនុញ្ញាតឱ្យបញ្ចូលឧស្ម័នឥន្ធនៈតាមធុងសម្រាប់លក់ចែកចាយក្នុងបរិវេណស្ថានីយ
៤. ពោងឧស្ម័នឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧,៥០ម៉ែត្រ ពីរបងព្រំដី
៥. ទុយោចាក់ប្រេង និងឧស្ម័នឥន្ធនៈមិនត្រូវមានប្រវែងលើស ពី៦ម៉ែត្រ
៦. ត្រូវមានគំនូសសញ្ញាសម្រាប់ចំណតរថយន្តស៊ីទែនផ្ទេរប្រេង និងឧស្ម័នឥន្ធនៈ
៧. ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក
៨. ត្រូវមានស្លាកសញ្ញាបម្រាម ស្ដីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់ និងផ្ទាំងព័ត៌មាននីតិវិធីនៃការផ្ទេរប្រេង និងឧស្ម័នឥន្ធនៈ
៩. ការរៀបចំទុកដាក់ ពោងឧស្ម័នឥន្ធនៈ ត្រូវយកចិត្តទុកដាក់ឱ្យបានខ្ពស់បំផុត ដោយធ្វើយ៉ាងណាឱ្យមានភាពសមស្របតាមសារាចរលេខ ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨របស់ក្រសួងរ៉ែ និងថាមពល។

**ប្រការ៥.**_

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្ដីណែនាំរបស់ក្រសួងរ៉ែ និងថាមពល ក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.**_

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពល មុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.**_

ម្ចាស់ស្ថានីយត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាស នៅក្នុងសប្ដាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្ដាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពល។

**ប្រការ៨.**_

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែនិងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធិភាពខ្ពស់។

**ប្រការ៩.**_

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន អំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល រយៈពេល១ (មួយ) ខែយ៉ាងតិចមុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាព ស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយលេខ ០៧៤០ រ៉ែ.អប្រក.លអ.....ចុះថ្ងៃទី.....២២............ខែ...ធ្នូ...........ឆ្នាំ២០២០...............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ០៧៤០ រ៉ែ.អប្រក.លអ ចុះថ្ងៃទី....២២.....ខែ..ធ្នូ..............ឆ្នាំ២០២០....នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពល ខេត្តបាត់ដំបង និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.អង្គារ...៨កើត....ខែ....បុស្ស....ឆ្នាំជូត..ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...២២.....ខែ...ធ្នូ..........ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តបាត់ដំបង
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខៈ ០៧៤១ រថ.អប្រក.ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
លេខ ០៧៤១ រថ.អប្រក.លអ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០២០

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

